C A L I F O R N I A

DEPARTMENT OF JUSTICE

VICTIMS' SERVICES UNIT

### ច្បាប់ស្តីពីកម្រងសិទ្ធិឯកជនរបស់ជនរងគ្រោះ ឆ្នាំ 2008

# បណ្ណ Marsy និងធនធាន

### ដើម្បីផ្តល់សិទ្ធិទទួលបានយុត្តិធម៌ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ដល់ជនរងគ្រោះ

| | |
|---|---|
| ឈ្មោះមន្ត្រី៖ | ទូរសព្ទ៖ |
| ឈ្មោះរដ្ឋអាជ្ញា៖ | ទូរសព្ទ៖ |
| របាយការណ៍ប៉ូលិសលេខ៖ | តុលាការជាន់ខ្ពស់លេខ៖ |
| ឈ្មោះចុងចោទ៖ | ថ្ងៃខែឆ្នាំកំណើត៖ |

នៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2008 ប្រជាជនរដ្ឋ California បានអនុម័តសំណើ 9 ច្បាប់ស្តីពីកម្រងសិទ្ធិឯកជនរបស់ជនរងគ្រោះឆ្នាំ 2008៖ ច្បាប់ Marsy វិធានការនេះបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋ California ដើម្បីផ្តល់សិទ្ធិបន្ថែមដល់ជនងរងគ្រោះ។ បណ្ណនេះមានផ្នែកជាក់លាក់អំពីធនធាន និងកម្រងសិទ្ធិឯកជនរបស់ជនរងគ្រោះ។ ជនរងគ្រោះនៃបទឧក្រិដ្ឋអាចទទួលបានព័ត៌មានបន្ថែមទាក់ទងនឹងច្បាប់ Marsy និងព័ត៌មានមជ្ឈមណ្ឌលជំនួយសាក្សីជនរងគ្រោះក្នុងមូលដ្ឋានដោយទាក់ទងទៅអង្គភាពសេវាកម្មជនរងគ្រោះនៃអគ្គមេធាវីតាមរយៈលេខ 1-877-433-9069 ឬតាមរយៈវិបសាយ www.oag.ca.gov/victimservices/contact។

ក្រោមរដ្ឋធម្មនុញ្ញនៃរដ្ឋ California 'ជនរងគ្រោះ' ត្រូវបានឱ្យនិយមន័យថាជា "បុគ្គលដែលរងគ្រោះដោយផ្ទាល់ ឬរងការគំរាមកំហែងលើរាងកាយ ចិត្តសាស្ត្រ ឬហិរញ្ញវត្ថុដោយសារការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬទង្វើល្មើសច្បាប់។ ពាក្យ 'ជនរងគ្រោះ' ក៏រួមបញ្ចូលសហព័ទ្ធ ឪពុកម្តាយ កូនៗ បងប្អូនបង្កើត ឬអាណាព្យាបាលរបស់បុគ្គលនោះ និងរួមបញ្ចូលទាំងអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានស្លាប់ ជាអនីតិជន ឬអសមត្ថភាពរាងកាយ ឬផ្លូវចិត្តផងដែរ។  ពាក្យ 'ជនរងគ្រោះ' មិនរួមបញ្ចូលបុគ្គលដែលកំពុងជាប់ឃុំដោយសារបទល្មើស ជនជាប់ចោទ ឬបុគ្គលដែលតុលាការរកឃើញថានឹងមិនធ្វើទង្វើដែលជាឧត្តមប្រយោជន៍របស់ជនរងគ្រោះទេ។" (Cal. Const., art. I, § 28(e).)

## ធនធានជនរងគ្រោះទូទាំងរដ្ឋ

**សេវាកម្មការពារមនុស្សពេញវ័យ៖** ទីភ្នាក់ងារនេះបូជាដើម្បីការពារសុខភាព និងសុវត្ថិភាពរបស់មនុស្សចាស់ និងមនុស្សពេញវ័យនៅក្នុងបន្ទុកដែលទទួលរងការមិនយកចិត្តទុកដាក់ ការរំលោភបំពាន ឬការកេងប្រវ័ញ្ច។ ដើម្បីរាយការណ៍អំពីការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់ ឬដើម្បីភ្ជាប់ទំនាក់ទំនងទៅកាន់សេវាកម្មការពារមនុស្សពេញវ័យនៅក្នុងខោនធីរបស់អ្នក សូមទូរសព្ទទៅលេខ 1-833-401-0832។

**ក្រសួងកែប្រែ និងស្ដារនីតិសម្បទារដ្ឋ CA ការិយាល័យសិទ្ធិ និងសេវាកម្មជនរងគ្រោះ និងអ្នករួចជីវិត (OVSRS)៖** ទីភ្នាក់ងារនេះផ្តល់ព័ត៌មានអំពីសវនាការការដោះលែងមុនកំណត់មានលក្ខខណ្ឌ លក្ខខណ្ឌសម្រាប់ការដោះលែងមុនកំណត់ ការផ្លាស់ប្តូរស្ថានភាពឃុំខ្លួន និងសំណងនៅពេលអ្នកប្រព្រឹត្តល្មើសស្ថិតក្នុងពន្ធនាគាររដ្ឋ California។ បើសិនជាអ្នកមានសំណួរអ្វី ឬត្រូវការជំនួយ សូមទូរសព្ទទៅលេខ 1-877-256-6877 ឬផ្ញើអ៊ីមែលទៅ www.cdcr.ca.gov/victim_services

**កម្មវិធីសំណងជនរងគ្រោះ៖** ក្រុមប្រឹក្សាសំណងជនរងគ្រោះរដ្ឋ California (CalVCB) ជាអ្នកបង់ប្រាក់ជម្រើសចុងក្រោយ។ បើសិនជាអ្នកគ្រប់តាមលក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបាន នោះ CalVCB អាចជួយបានដោយការទូទាត់សម្រាប់ការចំណាយដែលបណ្តាលមកពីបទឧក្រិដ្ឋ។ សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបាន បទឧក្រិដ្ឋដែលរ៉ាប់រងដោយ CalVCB និងការចំណាយដែលមានសិទ្ធិ សូមទាក់ទងមជ្ឈមណ្ឌលសាក្សីជនរងគ្រោះក្នុងមូលដ្ឋានរបស់អ្នក ឬ CalVCB ដោយផ្ទាល់តាមរយៈលេខ 1-800-777-9229 ឬចូលទៅកាន់វិបសាយ www.victims.ca.gov

**មជ្ឈមណ្ឌលធនធានជនរងគ្រោះនៃរដ្ឋ California៖** ផ្តល់ឱ្យជនរងគ្រោះនូវសិទ្ធិទទួលបានព័ត៌មាន ធនធានសម្រាប់ជនរងគ្រោះនៅក្នុងតំបន់ភូមិសាស្ត្ររបស់ពួកគេ និងព័ត៌មានអំពីសំណង។ បើសិនជាអ្នកមានសំណួរអ្វី ឬត្រូវការជំនួយ សូមទូរសព្ទទៅលេខ 1-800-VICTIMS ឬផ្ញើអ៊ីមែលទៅកាន់ www.1800victims.org

**សេវាកម្មបញ្ជូនបន្តនៃរដ្ឋ California៖** ទីភ្នាក់ងារនេះផ្តល់ជំនួយផ្នែកប្រាស្រ័យទាក់ទងដែលមានការបណ្តុះបណ្តាលជាពិសេសសម្រាប់អ្នកហៅទូរសព្ទ ឬនិយាយមិនច្បាស់ ថ្លង់ ឬត្រចៀកធ្ងន់។ បើសិនជាអ្នកមានសំណួរអ្វីមួយ ឬត្រូវការជំនួយ សូមហៅទៅលេខ 711 ឬលេខ 1-800-735-2929។

**មជ្ឈមណ្ឌលជំនួយសាក្សី/ជនរងគ្រោះ៖** ដើម្បីទទួលបានព័ត៌មានអំពីមជ្ឈមណ្ឌលជំនួយសាក្សី/ជនរងគ្រោះនៅក្នុងមូលដ្ឋានរបស់អ្នក ការតស៊ូមតិ ព័ត៌មានអំពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ និងធនធានផ្សេងទៀតនៅក្នុងតំបន់ភូមិសាស្ត្ររបស់អ្នក សូមទាក់ទងអង្គភាពសេវាកម្មជនរង្គ្រោះរបស់អគ្គមេធាវីតាមរយៈលេខ 1-877-433-9069 ចូលទៅកាន់វិបសាយ www.oag.ca.gov/VictimServices។

**កម្មវិធីយុត្តិធម៌បែបស្តារឡើងវិញនៅក្នុងសហគមន៍៖** តាមក្រមព្រហ្មទណ្ឌរដ្ឋ CA ផ្នែកទី 679.02 និង 679.027, "យុត្តិធម៌បែបស្តារឡើងវិញ" លើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ ដំណើរជាសះស្បើយ និងការស្តារនៅពេលដែលគ្រោះថ្នាក់បានកើតឡើង។ ដំណើរការទាំងនេះអាចរួមមានការប្រជុំដែលមានការសម្របសម្រួលដែលមានបុគ្គលដែលរងគ្រោះ បុគ្គលដែលបង្កគ្រោះថ្នាក់ ក្រុមគ្រួសាររបស់ពួកគេ និងសមាជិកសហគមន៍ ដើម្បីស្វែងរកមូលហេតុឫសគល់ និងផលប៉ះពាល់នៃគ្រោះថ្នាក់ និងដើម្បីគាំទ្រឱ្យមានការទទួលខុសត្រូវ និងដំណើរជាសះស្បើយ។ ដំណើរការយុត្តិធម៌បែបស្តារឡើងវិញ ជារឿយៗធ្វើឱ្យមានការយល់ដឹងស៊ីជម្រៅអំពីគ្រោះថ្នាក់ដែលបានបង្កឡើង ការបង្ហាញការទទួលខុសត្រូវប្រកបដោយអត្ថន័យ និងការព្រមព្រៀងធ្វើចំណាត់ការជាក់លាក់ដើម្បីស្តារការខូចខាត សេវាកម្មផ្ទាល់ខ្លួន ឬសហគមន៍ ការចូលរួមក្នុងការងារ ឬការប្រឹក្សា និងការទូទាត់សំណង។ បើសិនជាអ្នកចាប់អារម្មណ៍ចង់ស្វែងយល់ពីកម្មវិធីយុត្តិធម៌បែបស្តារឡើងវិញរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ឬនៅក្នុងសហគមន៍នៅក្នុងខោនធីរបស់អ្នក សូមទាក់ទងអង្គភាពសេវាកម្មជនរងគ្រោះរបស់អគ្គមេធាវីតាមរយៈលេខ 1-877-433-9069 ឬចូលទៅកាន់វិបសាយរបស់យើងតាមអាសយដ្ឋានតាម www.oag.ca.gov/victimservices/contact។

## ធនធានជនរងគ្រោះជាតិ

**មជ្ឈមណ្ឌលជាតិសម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ៖** 1-202-467-8700 • victimsofcrime.org

# កម្រងសិទ្ធិឯកជនរបស់ជនរងគ្រោះ

## រដ្ឋធម្មនុញ្ញរដ្ឋ California មាត្រា I ផ្នែកទី 28(b)

ដើម្បីរក្សា និងការពារសិទ្ធិទទួលបានយុត្តិធម៌ និងនីតិវិធីត្រឹមត្រូវតាមច្បាប់របស់ជនរងគ្រោះ ជនរងគ្រោះត្រូវមានសិទ្ធិដូចខាងក្រោម៖

1. ទទួលការប្រព្រឹត្តដាក់ដោយភាពយុត្តិធម៌ និងក្តីគោរពចំពោះឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់គាត់ និងគ្មានការបំភិតបំភ័យ ការបៀតបៀន និងការរំលោភបំពាន នៅពេញមួយដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ឬយុត្តិធម៌អនីតិជន។

2. ទទួលបានការការពារយ៉ាងសមស្របពីចុងចោទ និងបុគ្គលដែលធ្វើសកម្មភាពជំនួសឱ្យចុងចោទ។

3. ឱ្យគេគិតគូរពីសុវត្ថិភាពរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះនៅក្នុងការកំណត់ចំនួនប្រាក់ធានា និងលក្ខខណ្ឌនៃការដោះលែងសម្រាប់ជនជាប់ចោទ។

4. បង្ការការលាតត្រដាងព័ត៌មានសម្ងាត់ ឬកំណត់ត្រាទៅកាន់ជនជាប់ចោទ មេធាវីជនជាប់ចោទ ឬបុគ្គលផ្សេងទៀតដែលធ្វើសកម្មភាពជំនួសមុខឱ្យជនជាប់ចោទ ដែលគេអាចប្រើដើម្បីស្វែងរកទីតាំង ឬបៀតបៀនជនរងគ្រោះ ឬក្រុមគ្រួសារជនរងគ្រោះ ឬដែលលាតត្រដាងទំនាក់ទំនងសម្ងាត់ដែលបានធ្វើឡើងក្នុងអំឡុងពេលព្យាបាលវេជ្ជសាស្ត្រ ឬការប្រឹក្សាយោបល់ ឬត្រូវបានការពារ ឬរក្សាការសម្ងាត់ដោយច្បាប់។

5. បដិសេធការសម្ភាស ការយកសក្ខីកម្ម ឬសំណើដោះដូរភស្តុតាងដោយជនជាប់ចោទ មេធាវីជនជាប់ចោទ ឬបុគ្គលផ្សេងទៀតដែលធ្វើសកម្មភាពជំនួសឱ្យជនជាប់ចោទ និងដាក់លក្ខខណ្ឌសមស្របលើការអនុវត្តនៃការសម្ភាសដែលជនរងគ្រោះយល់ព្រម។

6. ចំពោះការជូនដំណឹងសមស្រប និងពិភាក្សាដោយសមស្របជាមួយទីភ្នាក់ងារអយ្យការ តាមសំណើ ទាក់ទងនឹងការចាប់ខ្លួនជនជាប់ចោទ បើសិនជារដ្ឋអាជ្ញាដឹង ការចោទប្រកាន់ដែលបានដាក់ ការកំណត់ថាតើត្រូវធ្វើបត្យាប័នជនជាប់ចោទដែរឬទេ ទទួលបានការជូនដំណឹង និងព័ត៌មានមុនពេលមានការសម្រេចចិត្តមុនការជំនុំជម្រះណាមួយនៃសំណុំរឿង តាមសំណើ។

7. ចំពោះការជូនដំណឹងសមស្របអំពីចំណាត់ការជាសាធារណៈទាំងអស់ រួមទាំងចំណាត់ការលើការប្រព្រឹត្តល្មើស តាមសំណើ ដែលជនជាប់ចោទ និងរដ្ឋអាជ្ញាមានសិទ្ធិចូលរួម និងអំពីនីតិវិធីដោះលែងមុនកំណត់មានលក្ខខណ្ឌ ឬនីតិវិធីដោះលែងក្រោយការកាត់ទោសផ្សេងទៀតទាំងអស់ និងមានវត្តមាននៅក្នុងចំណាត់ការទាំងអស់នោះ។

8. ឱ្យគេស្តាប់មតិយោបល់ តាមសំណើ នៅក្នុងចំណាត់ការណាមួយ រួមទាំងចំណាត់ការលើការប្រព្រឹត្តល្មើស ដោយមានការសម្រេចដោះលែងក្រោយការចាប់ខ្លួន ចម្លើយជនជាប់ចោទ ការកាត់ទោស ការសម្រេចចិត្តដោះលែងក្រោយការកាត់ទោស ឬចំណាត់ការណាមួយដែលសិទ្ធិរបស់ជនរងគ្រោះកំពុងត្រូវបានលើកឡើង។

9. ទទួលការកាត់ក្តីឆាប់រហ័ស និងការបញ្ចប់សំណុំរឿងឆាប់រហ័ស និងជាស្ថាពរ ព្រមទាំងនីតិវិធីដែលពាក់ព័ន្ធណាមួយក្រោយការសម្រេចរបស់តុលាការ។

10. ផ្តល់ព័ត៌មានដល់មន្រ្តីផ្នែកព្យួរទោសមានលក្ខខណ្ឌក្នុងការស៊ើបអង្កេតមុនការកាត់ទោស ពាក់ព័ន្ធនឹងផលប៉ះពាល់នៃបទល្មើសលើជនរងគ្រោះ និងក្រុមគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងអនុសាសន៍ទាក់ទងនឹងការកាត់ទោសណាមួយ មុនពេលមានការកាត់ទោសជនជាប់ចោទ។

11. ទទួលបានរបាយការណ៍មុនការកាត់ទោស តាមសំណើ នៅពេលដែលរបាយការណ៍នោះមានសម្រាប់ជនជាប់ចោទ លើកលែងតែផ្នែកណាដែលត្រូវបានចាត់ទុកជាការសម្ងាត់ដោយច្បាប់។

12. ទទួលបានព័ត៌មាន តាមសំណើ អំពីការផ្តន្ទាទោស ការកាត់ទោស ទីកន្លែង និងពេលវេលាឃុំខ្លួន ឬការសម្រេចទោសផ្សេងទៀតចំពោះជនជាប់ចោទ ថ្ងៃកំណត់ដោះលែងជនជាប់ចោទ និងការដោះលែង ឬការរត់គេចខ្លួនរបស់ជនជាប់ចោទពីការឃុំឃាំង។

13. ទទួលសំណង។

    A. វាជាចេតនាច្បាស់លាស់របស់ប្រជាជននៃរដ្ឋ California ដែលមនុស្សទាំងអស់ដែលរងការខាតបង់ដោយសារសកម្មភាពឧក្រិដ្ឋកម្ម មានសិទ្ធិស្វែងរក និងទទួលបានសំណងពីបុគ្គលដែលត្រូវបានកាត់ទោសពី បទឧក្រិដ្ឋដែលបណ្តាលឱ្យពួកគេរងការខាតបង់នោះ។

    B. សំណងត្រូវតែបង្គាប់យកពីជនល្មើសដែលត្រូវបានកាត់ទោសនៅក្នុងគ្រប់សំណុំរឿងទាំងអស់ ដោយមិនគិតពីទោសដែលបានដាក់ ឬការសម្រេចចិត្តណាមួយឡើយ ដែលជនរងគ្រោះដោយឧក្រិដ្ឋកម្មរងការខាតបង់។

    C. រាល់ការទូទាត់ជារូបិយវត្ថុ លុយកាក់ និងទ្រព្យសម្បត្តិទាំងអស់ដែលប្រមូលបានពីបុគ្គលណាម្នាក់ដែលត្រូវបានបង្គាប់ឱ្យទូទាត់សំណង ត្រូវតែប្រើប្រាស់សម្រាប់ទូទាត់ចំនួនទឹកប្រាក់ដែលបានបង្គាប់ជាសំណងដល់ជនរងគ្រោះជាមុនសិន។

14. ឱ្យគេប្រគល់ទ្រព្យសម្បត្តិមកវិញឆាប់រហ័ស នៅពេលដែលមិនចាំបាច់ទុកជាភស្តុតាងតទៅទៀត។

15. ទទួលបានព័ត៌មានអំពីនីតិវិធីដោះលែងមុនកំណត់មានលក្ខខណ្ឌ ចូលរួមក្នុងដំណើរការដោះលែងមុនកំណត់មានលក្ខខណ្ឌ ផ្តល់ព័ត៌មានដល់អាជ្ញាធរផ្នែកដោះលែងមុនកំណត់មានលក្ខខណ្ឌដើម្បីឱ្យគេពិចារណាមុនការដោះលែងអ្នកប្រព្រឹត្តល្មើសមុនកំណត់មានលក្ខខណ្ឌ ឬការដោះលែងផ្សេងទៀត តាមសំណើ។

16. ឱ្យគេគិតគូរពីសុវត្ថិភាពរបស់ជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងសាធារណជនមុនការដោះលែងមុនកំណត់មានលក្ខខណ្ឌ ឬការសម្រេចចិត្តដោះលែងក្រោយការសម្រេចផ្សេងទៀត។

17. ទទួលបានព័ត៌មានអំពីសិទ្ធិដែលមាននៅក្នុងកថាខណ្ឌ (1) ដល់ (16)។

ជនរងគ្រោះ មេធាវីដែលជនរងគ្រោះបានជួល អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ឬរដ្ឋអាជ្ញាអាចអនុវត្តសិទ្ធិខាងលើនៅក្នុងតុលាការជម្រះក្តី ឬតុលាការឧទ្ធរណ៍ដែលមានយុត្តាធិការលើសំណុំរឿងនេះទាក់ទងនឹងបញ្ហាសិទ្ធិតាមសំណើរបស់ជនរងគ្រោះ។ តុលាការត្រូវមានចំណាត់ការឆាប់រហ័សលើសំណើបែបនោះ។

(Cal. Const., art. I, § 28(c)(1).)